# ផែនការសកម្មភាព

# អភិវឌ្ឍការស្រាវជ្រាវនៃស.ភ.ន.វ.ស

## សេចក្តីផ្តើម

ផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវនៃសភនវស បង្កើតឡើងផ្អែកលើគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំដែលបានទទួលការឯកភាពក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ គោលនយោបាយនេះជំរុញការស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ផែនការយុទ្ធសាស្ត្រនៃស.ភ.ន.វ.ស ឆ្នាំ២០១៥-២០១៨ គោលនយោបាយស្រាវជ្រាវនៃស.ភ.ន.វ.ស និងផែនការសកម្មភាពរបស់ស.ភ.ន.វ.ស ដែលអនុម័តនាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥។ ផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវនៃស.ភ.ន.វ.ស បានបង្ហាញពីសកម្មភាព និងកម្មវិធីអនុវត្តដើម្បីសម្រេចឲ្យបាននូវការអនុវត្តគោលនយោបាយស្រាវជ្រាវ ដែលបង្កើតឲ្យមានវប្បធម៌នៃការស្រាវជ្រាវក្នុងគោលដៅលើកកម្ពស់គុណភាព សមត្ថភាពស្រាវជ្រាវរបស់មន្ត្រីរាជការ បុគ្គលិក សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងនិស្សិតនៅស.ភ.ន.វ.ស។

ផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវនៃស.ភ.ន.វ.ស មានគោលបំណងលើកកម្ពស់សមត្ថភាពស្រាវជ្រាវជាពិសេសក្នុងគោលដៅសម្រេចឲ្យបានគុណភាពអប់រំតាមរយៈការបណ្តុះបណ្តាល ដោយជំរុញឲ្យមានវប្បធម៌ស្រាវជ្រាវនៅក្នុង ស.ភ.ន.វ.ស និងធានាឲ្យបាននូវការអនុវត្តគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា និងក្រមសីលធម៌នៃការស្រាវជ្រាវ។ ផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវនៃស.ភ.ន.វ.ស ផ្តោតសំខាន់ទៅលើការធានាគុណភាពសមត្ថភាពអប់រំ ដោយជំរុញឲ្យមានការស្រាវជ្រាវ ក្នុងគោលបំណងកសាងឲ្យបាននូវឯកសារសម្រាប់ការសិក្សា និងការស្រាវជ្រាវដល់អ្នកជំនាន់ក្រោយ។

សាកលវិទ្យាល័យមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងការិយាល័យពាក់ព័ន្ធទាំងអស់ ចូលរួមគាំទ្រ អនុវត្តនូវផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវនេះឲ្យបានជោគជ័យ និងទទួលស្គាល់ថាការស្រាវជ្រាវ គឺពិតជាធានាបាននូវនិរន្តភាពនៃគុណភាពអប់រំនៅ ស.ភ.ន.វ.ស។

ផែនការសកម្មភាពអភិវឌ្ឍការស្រាវជ្រាវរបស់ស.ភ.ន.វ.ស បានកំណត់បែងចែកជាសកម្មភាពចម្បងៗចំនួន៦ និងសកម្មភាពរងមួយចំនួនដើម្បីគាំទ្រកិច្ចដំណើរការ ការស្រាវជ្រាវរួមមានៈ

១. លើកកម្ពស់សមត្ថភាពស្រាវជ្រាវសម្រាប់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ

២. លើកកម្ពស់គុណភាពអប់រំ និងនវានុវត្តតាមរយៈការសិក្សាស្រាវជ្រាវ

៣. ជំរុញការស្រាវជ្រាវគ្រប់កម្រិត និងសហប្រតិបត្តិការអន្តរជាតិ

៤. និរន្តរភាពនៃការស្រាវជ្រាវ

៥. កម្មសិទ្ធិបញ្ញា និងក្រមសីលធម៌នៃការស្រាវជ្រាវ

៦.ចងក្រង និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ

**<u>សកម្មភាពទី១.លើកកម្ពស់សមត្ថភាពស្រាវជ្រាវសម្រាប់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាជ្រាវ</u>**

សកម្មភាពរងទី១.១ រៀបចំកម្មវិធីបណ្តុះបណ្តាលបន្តដល់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ

សកម្មភាពរងទី១.២ រៀបចំកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ

សកម្មភាពរងទី១.៣ អភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកដែលធ្វើការក្នុងវិស័យចាំបាច់

សកម្មភាពរងទី១.៤ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីប្រភេទនៃការស្រាវជ្រាវ

សកម្មភាពរងទី១.៥ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីតម្រូវការនៃការស្រាវជ្រាវ និងប្រភេទនៃការស្រាវជ្រាវវិទ្យាសាស្ត្រ

សកម្មភាពរងទី១.៦ រៀបចំកម្មវិធីផ្តល់ឱកាសឲ្យមានការស្រាវជ្រាវរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានា

សកម្មភាពរងទី១.៧ រៀបចំកម្មវិធីផ្តល់ឱកាសឲ្យមានបទបង្ហាញរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានា

**<u>សកម្មភាពទី២.លើកកម្ពស់គុណភាពអប់រំ និងនវានុវត្តតាមរយៈការសិក្សាស្រាវជ្រាវ</u>**

សកម្មភាពរងទី២.១ រៀបចំកម្មវិធីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើការស្រាវជ្រាវឯកជន ឬរួមគ្នា

សកម្មភាពរងទី២.២ រៀបចំកម្មវិធីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើបទបង្ហាញឯកជន ឬរួមគ្នា

សកម្មភាពរងទី២.៣ រៀបចំបង្កើតព្រឹត្តិបត្រ និងទស្សនាវដ្តីបច្ចេកទេសគ្រប់ប្រភេទ

សកម្មភាពរងទី២.៤ រៀបចំបង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល

សកម្មភាពរងទី២.៥ រៀបចំបង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល

**<u>សកម្មភាពទី៣.ជំរុញការស្រាវជ្រាវគ្រប់កម្រិត និងសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ</u>**

សកម្មភាពរងទី៣.១ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងផ្តល់ឱកាសអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើការស្រាវជ្រាវរួមគ្នា

សកម្មភាពរងទី៣.២ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងផ្តល់ឱកាសអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើបទបង្ហាញរួមគ្នា

សកម្មភាពរងទី៣.៣ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងគាំទ្រការស្រាវជ្រាវចំរុះពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សារវាងសាកលវិទ្យាល័យដៃគូ

សកម្មភាពរងទី៣.៤ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងលើកទឹកចិត្តចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវតាមរយៈការផ្លាស់ប្តូរលទ្ធផល និងបទពិសោធន៍លើការស្រាវជ្រាវ

**សកម្មភាពទី៤.កម្មសិទ្ធិបញ្ញា និងក្រមសីលធម៌នៃការស្រាវជ្រាវ**

សកម្មភាពរងទី៤.១ រៀបចំកម្មវិធីតាក់តែងគោលការណ៍ណែនាំស្តីពីក្រមសីលធំនៃការស្រាវជ្រាវ

សកម្មភាពរងទី៤.២ រៀបចំកម្មវិធីតាក់តែងគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា

សកម្មភាពរងទី៤.៣ រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវ

សកម្មភាពរងទី៤.៤ រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញា និងការស្រាវជ្រាវ

សកម្មភាពរងទី៤.៥ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីក្រមសីលធម៌នៃការស្រាវជ្រាវរបស់ស.ភ.ន.វ.ស

សកម្មភាពរងទី៤.៦ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញានៃស.ភ.ន.វ.ស

សកម្មភាពរងទី៤.៧ រៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលើកម្មសិទ្ធិបញ្ញាលើសំណើរស្រាវជ្រាវ ឬស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ

សកម្មភាពរងទី៤.៨ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យកម្មសិទ្ធិបញ្ញាលើសំណើ និងស្នាដៃស្រាវជ្រាវ

**សកម្មភាពទី៥.និរន្តរភាពនៃការស្រាវជ្រាវ**

សកម្មភាពរងទី៥.១ រៀបចំបង្កើតគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ

សកម្មភាពរងទី៥.២ រៀបចំបង្កើតក្រុមអ្នកស្រាវជ្រាវ

សកម្មភាពរងទី៥.៣ រៀបចំកម្មវិធីលើកទឹកចិត្តដល់បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

សកម្មភាពរងទី៥.៤ ផ្តល់នូវធនធាន និងសម្ភារៈដែលចាំបាច់សម្រាប់ការស្រាវជ្រាវ

**សកម្មភាពទី៦.ចងក្រង និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ**

សកម្មភាពរងទី៦.១ រៀបចំបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ

សកម្មភាពរងទី៦.២ រៀបចំផ្សព្វផ្សាយនូវស្នាដៃស្រាវជ្រាវតាមប្រព័ន្ធWebsites របស់ស.ភ.ន.វ.ស

សកម្មភាពរងទី៦.៣ រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យស្រាវជ្រាវ(E-research) នៅ ស.ភ.ន.វ.ស

សកម្មភាពរងទី៦.៤ រៀបចំកម្មវិធីតាំងពិព័រណ៍ស្នាដៃស្រាវជ្រាវ

# សកម្មភាពចម្បងទី១

## លើកកម្ពស់សមត្ថភាពស្រាវជ្រាវសម្រាប់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ

## សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ

ដើម្បីសម្រេចបានការលើកកម្ពស់សមត្ថភាពស្រាវជ្រាវ សម្រាប់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ ស.ភ.ន.វ.ស ចាំបាច់ត្រូវលើកកម្ពស់គុណភាព សមត្ថភាពតាមសកម្មភាពមួយចំនួនដូចជា៖

**សកម្មភាពរងទី១.១ រៀបចំកម្មវិធីបណ្តុះបណ្តាលបន្តដល់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. បណ្តុះបណ្តាលបន្តអំពីគោលការណ៍ណែនាំ និង ប្រភេទនៃសំណើស្រាវជ្រាវគ្រប់ប្រភេទនៅ ស.ភ.ន.វ.ស។<br>2. បណ្តុះបណ្តាលបន្តអំពីវិធីសាស្ត្រនៃការត្រួតពិនិត្យ និងវាយតម្លៃលើសំណើស្រាវជ្រាវគ្រប់ប្រភេទនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីឱ្យគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវទទួលបាននូវវិធីសាស្ត្រមូលដ្ឋានក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើសំណើស្រាវជ្រាវគ្រប់ប្រភេទ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស មានគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីសម្រួលដល់ការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |

**សកម្មភាពរងទី១.២ រៀបចំកម្មវិធីបណ្តុះបណ្តាលបន្តសម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. បណ្តុះបណ្តាលបន្តដល់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវអំពីវិធីសាស្ត្រនៃការស្រាវជ្រាវ។<br>2. បណ្តុះបណ្តាលបន្តដល់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវអំពីការសរសេរគម្រោងស្រាវជ្រាវ និងសំណើស្រាវជ្រាវគ្រប់ប្រភេទ។<br>3. ស្វែងរកអាហារូបករណ៍ដើម្បីបញ្ជូនសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវទៅចូលរួមការបណ្តុះបណ្តាលវគ្គខ្លី និងវែងស្របតាមតម្រូវការរបស់ស.ភ.ន.វ.ស។<br>4. ស្វែងរកអាហារូបករណ៍ដើម្បីបញ្ជូនសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកនិងអ្នកស្រាវជ្រាវឲ្យទៅចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ។<br>5. ស្វែករកអាហារូបករណ៍ពីដៃគូអភិវឌ្ឍន៍ និងសាកលវិទ្យាល័យដៃគូដើម្បីឲ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវទទួលបានការបណ្តុះបណ្តាលបន្តលើចំណេះដឹងថ្មីៗស្របតាមការវិវត្តនៃរបបសេដ្ឋកិច្ច និងតម្រូវការសង្គម។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវមានសមត្ថភាព និងជំនាញក្នុងការចូលរួមដល់កិច្ចដំណើរការលើការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបានសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវមានជំនាញដើម្បីសម្រួលដល់ការងារស្រាវជ្រាវ ស្របតាមចក្ខុវិស័យ គោលបំណងនិងបេសសកម្មនៃ ស.ភ.ន.វ.ស ។ |

### សកម្មភាពរងទី១.៣ អភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកដែលធ្វើការក្នុងវិស័យចាំបាច់

| | |
|---|---|
| **កម្មវិធី** | 1. សិក្សាស្រាវជ្រាវ និងស្វែងយល់អំពីតម្រូវការសមត្ថភាពជំនាញចាំបាច់នៅ ស.ភ.ន.វ.ស។<br>2. កំណត់អំពីប្រភេទនៃសមត្ថភាពជំនាញដែលជាតម្រូវការចាំបាច់នៅ ស.ភ.ន.វ.ស។<br>3. កំណត់ចំនួនសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកទៅទទួលការបណ្តុះបណ្តាលបន្តលើវិស័យស្របតាមតម្រូវការចាំបាច់របស់ ស.ភ.ន.វ.ស។<br>4. បណ្តុះបណ្តាលបន្តដល់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកលើវិស័យស្របតាមតម្រូវការចាំបាច់របស់ ស.ភ.ន.វ.ស។<br>5. ធ្វើទំនាក់ទំនងស្វែងរកអាហារូបករណ៍ពីដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើការបណ្តុះបណ្តាលបន្តដល់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិក លើវិស័យស្របតាមតម្រូវការចាំបាច់របស់ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកមានសមត្ថភាពជំនាញលើវិស័យស្របតាមតម្រូវការចាំបាច់របស់ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបានសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកដែលមានជំនាញពិតប្រាកដបម្រើការក្នុងវិស័យចាំបាច់ដើម្បីសម្រួលដល់កិច្ចដំណើរការការងារស្រាវជ្រាវនៅស.ភ.ន.វ.ស។ |

### សកម្មភាពរងទី១.៤ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីប្រភេទនៃការស្រាវជ្រាវ

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយដល់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវឱ្យបានយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីប្រភេទនៃការស្រាវជ្រាវជាតម្រូវការចាំបាច់នៅស.ភ.ន.វ.ស។<br>2. កំណត់អំពីប្រភេទនៃប្រធានបទស្រាវជ្រាវជាតម្រូវការចាំបាច់នៅ ស.ភ.ន.វ.ស។<br>3. ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីប្រធានបទស្រាវជ្រាវដែលជាតម្រូវការចាំបាច់នៅ ស.ភ.ន.វ.ស និងកាលបរិច្ឆេទដើម្បីអញ្ជើញសរសេរសំណើស្រាវជ្រាវ និងកាលបរិច្ឆេទបញ្ចប់ការទទួលយកសំណើស្រាវជ្រាវ។ |
| **គោលដៅ** | 1. ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវបានយល់ដឹងច្បាស់អំពីប្រភេទនៃការស្រាវជ្រាវ និងលក្ខខណ្ឌនៃការសរសេរសំណើស្រាវជ្រាវដែលកំណត់ដោយ ស.ភ.ន.វ.ស។<br>2. ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវអាចកំណត់លទ្ធភាពក្នុងការចូលរួមសរសេរសំណើស្រាវជ្រាវគ្រប់ប្រភេទ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចទទួលបានស្នាដៃស្រាវជ្រាវគ្រប់ប្រភេទតាមតម្រូវការ។ |

### សកម្មភាពរងទី១.៥ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីតម្រូវការនៃការស្រាវជ្រាវ និងប្រភេទនៃការស្រាវជ្រាវវិទ្យាសាស្ត្រ

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីប្រភេទនៃការស្រាវជ្រាវ និងការស្រាវជ្រាវវិទ្យាសាស្ត្រនៅ ស.ភ.ន.វ.ស។<br>2. កំណត់អំពីប្រភេទនៃប្រធានបទស្រាវជ្រាវជាអាទិភាពនៅ ស.ភ.ន.វ.ស។<br>3. ផ្សព្វផ្សាយអំពីប្រភេទនៃប្រធានបទស្រាវជ្រាវជាអាទិភាពនៅ ស.ភ.ន.វ.ស។<br>4. ទទួលសំណើស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីអញ្ជើញឱ្យសរសេរសំណើស្រាវជ្រាវគ្រប់ប្រភេទស្របតាមតម្រូវការរបស់ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចបានស្នាដៃស្រាវជ្រាវប្រកបដោយគុណភាពអាចចូលរួមប្រកួតប្រជែងនៅក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។ |

### សកម្មភាពរងទី១.៦ រៀបចំកម្មវិធីផ្តល់ឱកាសមានការស្រាវជ្រាវរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានា

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីការផ្តល់ឱកាស និងលក្ខខណ្ឌអនុញ្ញាតឱ្យមានការស្រាវជ្រាវរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានា។<br>2. កំណត់អំពីប្រភេទនៃប្រធានបទស្រាវជ្រាវរួមគ្នានៅ ស.ភ.ន.វ.ស។<br>3. ផ្សព្វផ្សាយអំពីកាលបរិច្ឆេទឱ្យសរសេរសំណើស្រាវជ្រាវរួមគ្នា និងកាលបរិច្ឆេទបញ្ចប់ការទទួលយកសំណើស្រាវជ្រាវរួមគ្នា។ |
| **គោលដៅ** | ដើម្បីបង្កើតស្នាដៃស្រាវជ្រាវរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានាស្របតាមទិសដៅរួមនៃការដាក់អនុវត្តនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចបាននូវស្នាដៃស្រាវជ្រាវរួមគ្នាដែលផ្តល់នូវគុណប្រយោជន៍ចំពោះការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។ |

### សកម្មភាពរងទី១.៧ រៀបចំកម្មវិធីផ្តល់ឱកាសឲ្យមានបទបង្ហាញរួមគ្នារវាងស្ថាប័នស្រាវជ្រាវនានា

| | |
|---|---|
| **កម្មវិធី** | 1. រៀបចំសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិដោយជំរុញឱ្យអ្នកស្រាវជ្រាវធ្វើបទបង្ហាញរួមគ្នាលើលទ្ធផលស្នាដៃស្រាវជ្រាវរួមគ្នាដែលទទួលបាននៅ ស.ភ.ន.វ.ស។<br>2. ជំរុញឲ្យធ្វើបទបង្ហាញលើលទ្ធផលស្នាដៃស្រាវជ្រាវរួមគ្នានៅក្នុងសន្និសីទអន្តរជាតិនៅបរទេស។ |
| **គោលដៅ** | 1. ដើម្បីជំរុញអ្នកស្រាវជ្រាវបង្ហាញសមត្ថភាព និងចូលរួមយ៉ាងសកម្មក្នុងការធ្វើបទបង្ហាញរួមគ្នា។<br>2. ដើម្បីជំរុញ និងផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវចែករំលែកបទពិសោធន៍ និងចំណេះដឹងថ្មីលើស្នាដៃស្រាវជ្រាវរួមគ្នា។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចបាននូវការលើកកម្ពស់សមត្ថភាពស្រាវជ្រាវរបស់សាស្ត្រាចារ្យ មន្ត្រីរាជការបុគ្គលិក និងអ្នកស្រាវជ្រាវ។ |

## សកម្មភាពចម្បងទី២.

## លើកកម្ពស់គុណភាពអប់រំ និងនវានុវត្តន៍តាមរយៈការសិក្សាស្រាវជ្រាវ

ដើម្បីសម្រេចបានការលើកកម្ពស់គុណភាពអប់រំ និងនវានុវត្តន៍តាមរយៈការសិក្សាស្រាវជ្រាវ ស.ភ.ន.វ.ស ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចជា៖

### សកម្មភាពរងទី២.១ រៀបចំកម្មវិធីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើការស្រាវជ្រាវឯកជន ឬរួមគ្នា

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយដល់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកអំពីគុណប្រយោជន៍នៃការស្រាវជ្រាវ និងការស្រាវជ្រាវស្របទៅតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>2. អំពាវនាវឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើការស្រាវជ្រាវឯកជន ឬរួមគ្នាទៅតាមមុខវិជ្ជាបង្រៀន និងធ្វើការស្រាវជ្រាវស្របទៅតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>3. តម្រូវឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើការស្រាវជ្រាវឯកជន ឬរួមគ្នាទៅតាមមុខវិជ្ជាបង្រៀន និងកាស្រាវជ្រាវស្របទៅតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>4. កំណត់អំពីប្រភេទនៃប្រធានបទស្រាវជ្រាវចាំបាច់ សម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិក ដែលស្របទៅតាមមុខវិជ្ជាបង្រៀន និងកម្មវិធីបណ្តុះបណ្តាល នៅ ស.ភ.ន.ស.វ។ |
| **គោលដៅ** | ដើម្បីអភិវឌ្ឍកម្មវិធីសិក្សា លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងសមត្ថភាពស្រាវជ្រាវរបស់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចបាននូវកិច្ចដំណើការ ការងារស្រាវជ្រាវស្របតាមកម្មវិធីបណ្តុះបណ្តាល និងនវានុវត្តន៍តាមរយៈការសិក្សាស្រាវជ្រាវ។ |

### សកម្មភាពរងទី២.២ រៀបចំកម្មវិធីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើបទបង្ហាញឯកជន ឬរួមគ្នា

| | |
|---|---|
| **កម្មវិធី** | 1. លើកទឹកចិត្ត និងជំរុញឱ្យសាស្ត្រាចារ្យធ្វើបទបង្ហាញរួមគ្នាលើលទ្ធផលស្រាវជ្រាវដែលពាក់ព័ន្ធនិងមុខវិជ្ជាបង្រៀនជាលក្ខណៈឯកជន ឬរួមគ្នា រៀងរាល់បីខែ ឬ៦ខែម្តង។<br>2. លើកទឹកចិត្ត និងតម្រូវឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកធ្វើបទបង្ហាញជាឯកជន ឬរួមគ្នាលើស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ និងស្នាដៃស្រាវជ្រាវស្របតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | 1. ដើម្បីលើកកម្ពស់គុណភាពអប់រំ និងសមត្ថភាពស្រាវជ្រាវតាមរយៈការបង្កើតទម្លាប់ឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិក ធ្វើការស្រាវជ្រាវឯកជន ឬរួមគ្នាលើមុខវិជ្ជាបង្រៀន និងការស្រាវជ្រាវផ្សេងទៀត។<br>2. ដើម្បីលើកទឹកចិត្ត និងជំរុញឱ្យបង្ហាញសមត្ថភាពតាមរយៈការធ្វើបទបង្ហាញជាលក្ខណៈឯកជន ឬរួមគ្នាលើស្នាដៃស្រាវជ្រាវ។ |

| | |
|---|---|
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចទទួលបានសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកដែលមានសមត្ថភាព និងជំនាញក្នុងការធ្វើបទបង្ហាញលើស្នាដៃស្រាវជ្រាវដែលមានការទទួលស្គាល់ទាំងនៅក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។ |

## សកម្មភាពរងទី២.៣ រៀបចំបង្កើតព្រឹត្តិបត្រ និងទស្សនាវដ្តីបច្ចេកទេសគ្រប់ប្រភេទ

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីតម្រូវការនៃការតាក់តែងព្រឹត្តបត្រ និងទស្សនាវដ្តីបច្ចេកទេសស្របតាមផែនការយុទ្ធសាស្ត្រ និងសកម្មភាពរបស់ ស.ភ.ន.វ.ស។<br>2. កំណត់អំពីទិសដៅនៃការបោះពុម្ពផ្សាយព្រឹត្តិបត្រ និងប្រភេទនៃព្រឹត្តិបត្រដែលជាតម្រូវការចាំបាច់ នៅ ស.ភ.ន.វ.ស។<br>3. កំណត់អំពីទិសដៅនៃការបោះពុម្ពផ្សាយទស្សនាវដ្តីបច្ចេកទេស និងប្រភេទនៃទស្សនាវដ្តីបច្ចេកទេសដែលជាតម្រូវការចាំបាច់ នៅ ស.ភ.ន.វ.ស។<br>4. តាក់តែង និងកំណត់ពេលចេញផ្សាយនូវព្រឹត្តិបត្រប្រចាំ ស.ភ.ន.វ.ស។<br>5. តាក់តែង និងកំណត់ពេលចេញផ្សាយនូវទស្សនាវដ្តីបច្ចេកទេស ស្របទៅតាមជំនាញ និងកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស<br>6. បង្កើតក្រុមការងារព្រឹត្តបត្រ និងគោលការណ៍ណែនាំស្តីតួនាទីភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមការងារព្រឹត្តិបត្រនៅ ស.ភ.ន.វ.ស។<br>7. បង្កើតក្រុមការងារទស្សនាវដ្តីបច្ចេកទេស និងគោលការណ៍ណែនាំស្តីពីតួនាទីភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមការងារទស្សនាវដ្តីបច្ចេកទេសនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីបង្កើតឱ្យមានព្រឹត្តិបត្រ និងទស្សនាវដ្តីបច្ចេកទេសគ្រប់ប្រភេទស្របតាមតម្រូវការរបស់ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស មានព្រឹត្តិបត្រ និងទស្សនាវដ្តីបច្ចេកទេសគ្រប់ប្រភេទ ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវបន្តសម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក អ្នកស្រាវជ្រាវ និងនិស្សិតនៅ ស.ភ.ន.វ.ស។ |

## សកម្មភាពរងទី២.៤ រៀបចំបង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីទិសដៅនៃតម្រូវការ និងអត្ថប្រយោជន៍ចំពោះការបង្កើត សៀវភៅមេរៀនគោលគ្រប់ប្រភេទស្របតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>2. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។<br>3. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។<br>4. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច។<br>5. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍។<br>6. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ។ |

| | |
|---|---|
| | 7. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ។<br>8. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចព័ត៌មាន។<br>9. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រទេសចរណ៍ និងបដិសណ្ឋារកិច្ច។<br>10. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ។<br>11. ធ្វើបច្ចុប្បន្នភាពលើសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល និងការវិវត្តន៍នៃសេដ្ឋកិច្ច និងរបបសង្គមនៅកម្ពុជា។ |
| **គោលដៅ** | ដើម្បីឲ្យកម្មវិធីបណ្តុះបណ្តាលមានគុណភាពស្តង់ដារ និងមានលក្ខណៈឯកភាពគ្នានៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស មានសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល។ |

**សកម្មភាពរងទី២.៥ រៀបចំបង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាល**

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីតម្រូវការ និងអត្ថប្រយោជន៍ចំពោះការបង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>2. បង្កើតសៀវភៅគោលសម្រាប់ង្រៀនគ្រប់មុខវិជ្ជាសម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។<br>3. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។<br>4. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច។<br>5. បង្កើតសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍។<br>6. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ។<br>7. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រគណនេយ្យ។<br>8. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចពត៌មាន។<br>9. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រទេសចរណ៍ និងបដិសណ្ឋារកិច្ច។<br>10. បង្កើតសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ។<br>11. ធ្វើបច្ចុប្បន្នភាពលើសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជា។ |
| **គោលដៅ** | ដើម្បីកំណត់ទិសដៅរួមនៃការបណ្តុះបណ្តាល និងជាជំនួយដល់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកសម្រាប់ការបង្រៀនស្របតាមកម្មវិធីសិក្សានៅ ស.ភ.ន.វ.ស ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស មានសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជានៅ ស.ភ.ន.វ.ស។ |

# សកម្មភាពចម្បងទី៣

## ជំរុញការស្រាវជ្រាវគ្រប់កម្រិត និងសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការជំរុញការស្រាវជ្រាវគ្រប់កម្រិត និងសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ ស.ភ.ន.វ.ស ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

**សកម្មភាពរងទី៣.១ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើការស្រាវជ្រាវរួមគ្នា**

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីការជំរុញការស្រាវជ្រាវគ្រប់កម្រិត ការលើកទឹកចិត្ត និង ការផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើការស្រាវជ្រាវរួមគ្នា។<br>2. ផ្សព្វផ្សាយអំពីប្រភេទនៃការស្រាវជ្រាវជាតម្រូវការចាំបាច់ និងលក្ខខណ្ឌលើកទឹកចិត្តឱ្យការចូលរួមសរសេរសំណើស្រាវជ្រាវរួមគ្នារវាងអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ។<br>3. ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកំណត់លទ្ធភាព និងអំពាវនាវឲ្យមានការស្រាវជ្រាវរួមគ្នានៅក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។<br>4. កំណត់អំពីកាលបរិច្ឆេទអញ្ជើញឱ្យសរសេរសំណើស្រាវជ្រាវ និងកាលបរិច្ឆេទបញ្ចប់ការទទួលយកសំណើស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | 1. ដើម្បីផ្តល់ឱកាស និងបើកទូលាយឱ្យមានការស្រាវជ្រាវគ្រប់កម្រិត និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ។<br>2. ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗលើការស្រាវជ្រាវរួមគ្នានៅក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស បានបង្កើតទំនាក់ទំនងជំរុញកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវ និងផ្តល់ឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកទទួលបាននូវចំណេះដឹងថ្មីព្រមទាំងបទពិសោធន៍គ្រប់គ្រាន់ដើម្បីសម្រួលដល់ការស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |

**សកម្មភាពរងទី៣.២ រៀបចំកម្មវិធីកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងផ្តល់ឱកាសអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើបទបង្ហាញរួមគ្នា**

| | |
|---|---|
| **កម្មវិធី** | 1. លើកទឹកចិត្ត និងជំរុញឱ្យអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើបទបង្ហាញថ្នាក់ជាតិរួមគ្នាលើលទ្ធផលស្នាដៃស្រាវជ្រាវនៅក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ។<br>2. លើកទឹកចិត្ត និងជំរុញឱ្យអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិធ្វើបទបង្ហាញថ្នាក់តំបន់ ឬអន្តរជាតិរួមគ្នាលើលទ្ធផលនៃស្នាដៃស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីបង្កើតទំនាក់ទំនង និងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ ។ |
| **លទ្ធផល** | សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស ទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗតាមរយៈការធ្វើបទបង្ហាញលើលទ្ធផលស្នាដៃស្រាវជ្រាវក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។ |

**សកម្មភាពរងទី៣.៣ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងគាំទ្រការស្រាវជ្រាវចម្រុះពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សារវាងសាកលវិទ្យាល័យដៃគូ**

| | |
|---|---|
| **កម្មវិធី** | 1. ធ្វើទំនាក់ទំនងជាមួយសាកលវិទ្យាល័យដៃគូ ដើម្បីសិក្សាអំពីកម្មវិធីសិក្សា និងការអភិវឌ្ឍនៃកម្មវិធីសិក្សាថ្មីៗនៅសាកលវិទ្យាល័យដៃគូ។<br>2. សហការជាមួយសាកលវិទ្យាល័យដៃគូ និងដឹកនាំឱ្យមានការផ្សព្វផ្សាយ អំពីកម្មវិធីបណ្តុះបណ្តាលផ្សេងៗពីសាកលវិទ្យាល័យដៃគូនៅ ស.ភ.ន.វ.ស។<br>3. ផ្សព្វផ្សាយអំពីការផ្តល់ឱកាសឲ្យមានការស្រាវជ្រាវចម្រុះលើមុខវិជ្ជាសិក្សាស្របតាមកម្មវិធីបណ្តុះបណ្តាល និងស្របតាមការវិវត្តន៍នៃសេដ្ឋកិច្ច និងសង្គម។<br>4. កំណត់អំពីប្រភេទនៃការស្រាវជ្រាវចម្រុះលើមុខវិជ្ជាសិក្សាដែលជាតម្រូវការចាំបាច់នៅ ស.ភ.ន.វ.ស។<br>5. លើកទឹកចិត្ត និងកំណត់អំពីកាលបរិច្ឆេទអញ្ជើញឱ្យសរសេរសំណើស្រាវជ្រាវចម្រុះលើមុខវិជ្ជាសិក្សា និងកាលបរិច្ឆេទបញ្ចប់ការទទួលយកសំណើស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីរៀបចំអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបាននូវកម្មវិធីបណ្តុះណ្តាលថ្មីស្របតាមតម្រូវការចាំបាច់ ការវិវត្តន៍នៃសេដ្ឋកិច្ច និងរបបសង្គមនៅកម្ពុជា។ |

**សកម្មភាពរងទី៣.៤ រៀបចំកម្មវិធីជំរុញការស្រាវជ្រាវគ្រប់កម្រិត និងលើកទឹកចិត្តចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវតាមរយៈការផ្លាស់ប្តូរលទ្ធផល និងបទពិសោធន៍លើការស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. ផ្តល់ឱកាសឲ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារស្រាវជ្រាវ ដោយរៀបចំជាវេទិការស្រាវជ្រាវវិទ្យាសាស្ត្រ សំណើសុំមូលនិធិ និងដឹកនាំការអនុវត្តគម្រោងស្រាវជ្រាវនិងបោះពុម្ពផ្សាយរួមគ្នា។<br>2. ជំរុញឱ្យមានសិក្ខាសាលារួមគ្នាដើម្បីផ្លាស់ប្តូរលទ្ធផលស្រាវជ្រាវ និងចែករំលែកបទពិសោធន៍ថ្មីៗលើការងារស្រាវជ្រាវ។<br>3. លើកទឹកចិត្ត ដោយផ្តល់ជាកិត្តិយស ឬប័ណ្ណសរសើរ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ និងធ្វើការផ្សព្វផ្សាយលើស្នាដៃស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីធានានូវនិរន្តរភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវគ្រប់កម្រិតនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបាននូវបទពិសោធន៍ថ្មីៗលើការស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិលើការស្រាវជ្រាវ។ |

# សកម្មភាពចម្បងទី៤

## កម្មសិទ្ធិបញ្ញា និងក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីដាក់អនុវត្តនូវគោលនយោបាយស្រាវជ្រាវឱ្យមានប្រសិទ្ធិភាព ការពារមិនឲ្យមានការលួចចម្លងស្នាដៃ និងការបំពានទៅលើកម្មសិទ្ធិបញ្ញា ស.ភ.ន.វ.ស ចាំបាច់ត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

### សកម្មភាពរងទី៤.១ រៀបចំកម្មវិធីតាក់តែងគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវ

| | |
|---|---|
| **កម្មវិធី** | 1. បង្កើតក្រុមការងារតាក់តែងគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវ។<br>2. តាក់តែងគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ដាក់អនុវត្តគោលការណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវ ក្នុងគោលដៅធានាការអនុវត្តគោលនយោបាយស្រាវជ្រាវឱ្យមានប្រសិទ្ធិភាពនៅ ស.ភ.ន.វ.ស។ |

### សកម្មភាពរងទី៤.២ រៀបចំកម្មវិធីតាក់តែងគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា

| | |
|---|---|
| **កម្មវិធី** | 1. បង្កើតក្រុមការងារតាក់តែងគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា។<br>2. តាក់តែងគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា។ |
| **គោលដៅ** | ដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញានៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ដើម្បីអនុវត្តនូវគោលនយោបាយស្រាវជ្រាវឱ្យមានប្រសិទ្ធភាព និងបង្ការមិនឱ្យមានការបំពានទៅលើកម្មសិទ្ធិបញ្ញានៅ ស.ភ.ន.វ.ស។ |

### សកម្មភាពរងទី៤.៣ រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវ

| | |
|---|---|
| **កម្មវិធី** | 1. រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវទៅសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។<br>2. បណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវទៅសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកបានយល់ដឹង និងដាក់អនុវត្តក្រមសីលធម៌នៃការស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | អនុវត្តគោលនយោបាយស្រាវជ្រាវឱ្យមានប្រសិទ្ធភាព និងបង្ការមិនឲ្យមានការលួចចម្លងស្នាដៃស្រាវជ្រាវ។ |

**សកម្មភាពរងទី៤.៤ រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញា និងការស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញាទៅសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។<br>2. បណ្តុះបណ្តាលអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា និងការស្រាវជ្រាវទៅសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកបានយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញានៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | អនុវត្តនូវគោលនយោបាយស្រាវជ្រាវឱ្យមានប្រសិទ្ធិភាព និងបង្ការមិនឱ្យមានការបំពានទៅលើកម្មសិទ្ធិបញ្ញានៅ ស.ភ.ន.វ.ស។ |

**សកម្មភាពរងទី៤.៥ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីក្រមសីលធម៌នៃការស្រាវជ្រាវរបស់ ស.ភ.ន.វ.ស**

| | |
|---|---|
| **កម្មវិធី** | 1. ផ្សព្វផ្សាយអំពីក្រមសីលធម៌នៃការស្រាវជ្រាវទៅសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ។<br>2. បណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវ និងគុណប្រយោជន៍នៃការស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវបានយល់ដឹងអំពីក្រមសីលធម៌នៃការស្រាវជ្រាវ។ |
| **លទ្ធផល** | អនុវត្តគោលការណ៍ណែនាំស្តីពីក្រមសីលធម៌នៃការស្រាវជ្រាវឱ្យមានប្រសិទ្ធភាពនៅ ស.ភ.ន.វស។ |

**សកម្មភាពរងទី៤.៦ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា**

| | |
|---|---|
| **កម្មវិធី** | 1. រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា។<br>2. បណ្តុះបណ្តាលអំពីការស្រាវជ្រាវ និងគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា។ |
| **គោលដៅ** | ដើម្បីសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវ បានយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញា។ |
| **លទ្ធផល** | ស.ភ.ន.វ.ស អាចអនុវត្តគោលការណ៍ណែនាំស្តីពីកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធិភាព។ |

**សកម្មភាពរងទី៤.៧ រៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យកម្មសិទ្ធិបញ្ញាលើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ**

| | |
|---|---|
| **កម្មវិធី** | 1. បង្កើតប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលើសំណើស្រាវជ្រាវ ឬស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។<br>2. បណ្តុះបណ្តាលមន្ត្រីជំនាញអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលើសំណើស្រាវជ្រាវ ឬស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។ |
| **គោលដៅ** | ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យកម្មសិទ្ធិបញ្ញា ក្នុងគោលដៅបង្ការមិនឱ្យមានការលួចចម្លងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស មានប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យកម្មសិទ្ធិបញ្ញាដែលមានប្រសិទ្ធិភាព។ |

**សកម្មភាពរងទី៤.៨ រៀបចំកម្មវិធីផ្សព្វផ្សាយអំពីប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យកម្មសិទ្ធិបញ្ញាលើសំណើ និងស្នាដៃស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ដំណើការ និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យកម្មសិទ្ធិបញ្ញា លើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីឱ្យសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យលើសំណើ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យកម្មសិទ្ធិបញ្ញាលើសំណើ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទឱ្យកាន់តែមានប្រសិទ្ធភាព។ |

## សកម្មភាពចម្បងទី៥

## និរន្តរភាពនៃការស្រាវជ្រាវ

ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើការការងារស្រាវជ្រាវ ស.ភ.ន.វ.ស ចាំបាច់ត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

**សកម្មភាពរងទី៥.១ រៀបចំបង្កើតគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. បង្កើតគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនៅ ស.ភ.ន.វ.ស។<br>2. តាក់តែងគោលការណ៍ណែនាំស្តីពីតួនាទីភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ។ |
| **គោលដៅ** | ដើម្បីបង្កើតគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនៅ ស.ភ.ន.វ.ស |
| **លទ្ធផល** | ស.ភ.ន.វ.ស មានគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីសម្រួលដល់កិច្ចការស្រាវជ្រាវ នៅស.ភ.ន.វ.ស។ |

**សកម្មភាពរងទី៥.២ រៀបចំបង្កើតក្រុមអ្នកស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. បង្កើតក្រុមអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។<br>2. តាក់តែងគោលការណ៍ណែនាំស្តីពីតួនាទីភារកិច្ចរបស់ក្រុមអ្នកស្រាវជ្រាវ។<br>3. តម្រូវឱ្យក្រុមអ្នកស្រាវជ្រាវសរសេរកិច្ចការស្រាវជ្រាវគ្រប់ប្រភេទ ស្របតាមតម្រូវការរបស់ស.ភ.ន.វ.ស។<br>4. តម្រូវឱ្យក្រុមអ្នកស្រាវជ្រាវធ្វើបទបង្ហាញលើលទ្ធផលនៃស្នាដៃស្រាវជ្រាវគ្រប់ប្រភេទនៅស.ភ.ន.វ.ស ។ |
| **គោលដៅ** | ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើការការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបាននូវស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។ |

សកម្មភាពរងទី៥.៣ រៀបចំកម្មវិធីលើកទឹកចិត្តដល់បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

| | |
|---|---|
| **កម្មវិធី** | 1. តាក់តែងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្រៃលើស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។<br>2. រៀបចំកញ្ចប់ថវិកាច្បាស់លាស់ដើម្បីសម្រួលដល់ដំណើការការងារស្រាវជ្រាវ។<br>3. រៀបចំកម្មវិធីផ្សេងៗដើម្បីលើកទឹកចិត្តដល់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និងអ្នកស្រាវជ្រាវដើម្បីឲ្យការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស ដំណើការ។ |
| **គោលដៅ** | ដើម្បីធានានិរន្តភាពនៃការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបាននូវនិរន្តភាពនៃកិច្ចដំណើការការងារស្រាវជ្រាវ។ |

សកម្មភាពរងទី៥.៤ ផ្តល់ធនធាន និងសម្ភារៈដែលចាំបាច់សម្រាប់ការស្រាវជ្រាវ

| | |
|---|---|
| **កម្មវិធី** | 1. ផ្តល់ធនធានបណ្ណាល័យគ្រប់គ្រាន់ដើម្បីសម្រួលដល់ការស្រាវជ្រាវសម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកក្នុងការស្រាវជ្រាវ។<br>2. ផ្តល់ការតភ្ជាប់នូវបណ្តាញInternetគ្រប់គ្រាន់ដើម្បីសម្រួលដល់កិច្ចដំណើការ ការងារស្រាវជ្រាវ សម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ និងបុគ្គលិកក្នុងការស្រាវជ្រាវ។<br>3. ផ្តល់ម៉ាស៊ីន Photo Copy, ម៉ាស៊ីនComputer, ម៉ាស៊ីន Print និងសម្ភារៈផ្សេងៗទៀតដែលសម្រួលដល់ការងារស្រាវជ្រាវនៅ ស.ភ.ន.វ.ស។<br>4. កំណត់ទីតាំងនៃកិច្ចដំណើការការងារស្រាវជ្រាវដើម្បីសម្រួលដល់សាស្ត្រាចារ្យ មន្រីរាជការ និងបុគ្គលិកនៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីផ្តល់ភាពងាយស្រួលក្នុងកិច្ចដំណើការការងារស្រាវជ្រាវ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបាននូវនិរន្តភាពនៃកិច្ចដំណើការការងារស្រាវជ្រាវ។ |

## សកម្មភាពចម្បងទី៦

## ចងក្រង និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ

សកម្មភាពរងទី៦.១ រៀបចំបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ

| | |
|---|---|
| **កម្មវិធី** | 1. បោះពុម្ពផ្សាយព្រឹត្តិបត្រប្រចាំ ស.ភ.ន.វ.ស។<br>2. បោះពុម្ពផ្សាយទស្សនាវដ្តីបច្ចេកទេស គ្រប់ប្រភេទនៅ ស.ភ.ន.វ.ស។<br>3. បោះពុម្ពផ្សាយសៀវភៅមេរៀនគោលគ្រប់មុខវិជ្ជាស្របតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>4. បោះពុម្ពផ្សាយសៀវភៅគោលសម្រាប់បង្រៀនគ្រប់មុខវិជ្ជា ស្របតាមកម្មវិធីបណ្តុះបណ្តាលនៅ ស.ភ.ន.វ.ស។<br>5. បោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទដែលទទួលបាននៅ ស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីរៀបចំចងក្រងស្នាដៃស្រាវជ្រាវ និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ។ |
| **លទ្ធផល** | ស.ភ.ន.វ.ស ទទួលបានឯកសារស្រាវជ្រាវគ្រប់ប្រភេទស្របតាមកម្មវិធីបណ្តុះបណ្តាលសម្រាប់សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកនិងអ្នកស្រាវជ្រាវ។ |

**សកម្មភាពរងទី៦.២ រៀបចំផ្សព្វផ្សាយស្នាដៃស្រាវជ្រាវគ្រប់ប្រភេទតាមប្រព័ន្ធ Websites របស់ ស.ភ.ន.វ.ស**

| | |
|---|---|
| **កម្មវិធី** | 1. ចងក្រងស្នាដៃស្រាវជ្រាវគ្រប់ភេទ និងធ្វើការផ្សព្វផ្សាយតាមWebsites របស់ ស.ភ.វ.ន.ស។ |
| **គោលដៅ** | ដើម្បីចងក្រងឯកសារស្រាវជ្រាវតាមប្រព័ន្ធInternet( E-Library )។ |
| **លទ្ធផល** | ស.ភ.ន.វ.ស បង្កើតបាន E-library។ |

**សកម្មភាពរងទី៦.៣ រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យស្រាវជ្រាវ( E-research ) នៅ ស.ភ.ន.វ.ស**

| | |
|---|---|
| **កម្មវិធី** | 1. គ្រប់គ្រងការស្រាវជ្រាវតាមប្រព័ន្ធព័ត៌មានវិទ្យា។<br>2. បង្កើតការស្រាវជ្រាវឯកសារតាមបណ្តាញអេឡិចត្រូនិច។ |
| **គោលដៅ** | ដើម្បីបង្កើតការស្រាវជ្រាវឯកសារតាមបណ្តាញអេឡិចត្រូនិច។។ |
| **លទ្ធផល** | ស.ភ.ន.វ.ស បង្កើតបានការស្រាវជ្រាវឯកសារតាមបណ្តាញអេឡិចត្រូនិច។។ |

**សកម្មភាពរងទី៦.៤ រៀបចំកម្មវិធីតាំងពិព័រណ៍ស្នាដៃស្រាវជ្រាវ**

| | |
|---|---|
| **កម្មវិធី** | 1. តាំងពិព័រណ៍ស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ ដែលទទួលបាននៅស.ភ.ន.វ.ស។ |
| **គោលដៅ** | ដើម្បីផ្សព្វផ្សាយអំពីស្នាដៃស្រាវជ្រាវគ្រប់ប្រភេទដែលមាននៅ ស.ភ.ន.វ.ស។ |
| **លទ្ធផល** | ស.ភ.ន.វ.ស សម្រេចបានការផ្សព្វផ្សាយស្នាដៃស្រាវគ្រប់ប្រភេទ។ |